00656497

E9/16/3

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 25 / 03 / 2011
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**ញត្តិរបស់មេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ ដើម្បីគាំទ្រទៅនឹង**
**"សំណើរបស់មេធាវីការពារក្ដី លោក អៀង សារី ស្នើសុំបន្ថែមពេលវេលា**
**ដើម្បីដាក់បញ្ជីឯកសា និងវត្ថុតាង"**

---

ដាក់ដោយ៖
**មេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ**
ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS, QC

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
PICH Ang
Elisabeth SIMONNEAU FORT

ផ្ញើជូន៖
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន
ចៅក្រម ធូ មណី
ចៅក្រម យ៉ា សុខន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE

ផ្ញើជូន៖
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

១. នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១, មេធាវីការពារក្តីជនជាប់ចោទលោក អៀង សារីបានដាក់ "សំណើស្នើសុំបន្ថែមពេលវេលាដើម្បីដាក់នូវបញ្ជីឯកសារ និងវត្ថុតាងរបស់ខ្លួន" (**សំណើរបស់លោកអៀង សារី**) ដែលបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងដើម្បីអនុញ្ញាតឲ្យដាក់នូវបញ្ជីឯកសារ និងវត្ថុតាងនៅក្រោយពេលដែលសហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញនូវរឿងក្តីរបស់ពួកគេនៅសវនាការ ឬជម្រើសផ្សេងទៀត ដោយផ្តល់នូវពេលវេលាបន្ថែមទៀតចំនួន ៦០ថ្ងៃចាប់ពីថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីអំពីរចនាសម្ព័ន្ធនៃសវនាការ និង ដីកាបង្គាប់អំពីប្រធានបទដែលនឹងត្រូវលើកឡើង។

២. មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ (ជនជាប់ចោទ) សូមគាំទ្រ និងទទួលយកតាមអំណះអំណាងដែលបានលើកឡើងនៅក្នុងសំណើរបស់ក្រុមមេធាវីការពារក្តី លោក អៀង សារី ដែលស្នើសុំបន្ថែមពេលវេលាដើម្បីដាក់បញ្ជីឯកសារនិងវត្ថុតាង។តាមរយៈអំណះអំណាងដែលបានលើកឡើងរួចមកហើយនោះ មេធាវីការពារក្តីស្នើសុំឲ្យ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យមេធាវីការពារក្តីពន្យាពេលក្នុងការដាក់បញ្ជីឯកសារ និងវត្ថុតាងរបស់ខ្លួន រហូតទាល់តែសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញនូវបញ្ជីឯកសារ និងវត្ថុតាងរបស់ពួកគេសិន។ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យមេធាវីការពារក្តីនូវពេលវេលាបន្ថែមចំនួន ៤៥ថ្ងៃក្រោយពីបានទទួលបញ្ជីឯកសារ និងវត្ថុតាងរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី នឹងដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាងរបស់មេធាវីការពារក្តី ដើម្បីធានានូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ ដូចដែលបានធានាដោយវិធាន ២១ នៃវិធានផ្ទៃក្នុង និងបទដ្ឋានគតិយុត្តិសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀត ហើយដែល អ.វ.ត.កមានកាតព្វកិច្ចត្រូវអនុវត្តតាម។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature] |